ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៨៥/០៥-តាក ហ្វាត**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **កៅ ថាច**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងធុង**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន តាក ហ្វាត ហ្គាម៉ិន (ខេមបូឌា) អ៊ែលធីឌី**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៥៥៧ ៥៧៦ លេខទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក ហំ ភា | មេធាវីតំណាងដោយអាណត្តិ |
| ២- លោកស្រី ម៉ែន សុត្ថា | ប្រធានរដ្ឋបាល |
| ៣- លោក លើវ ម៉ាន់ | រដ្ឋបាល |
| ៤- លោក ជាតិ ខេមរា | មន្ត្រី GMAC |
| ៥- លោក សេង វុត្ថា | រដ្ឋបាល |
| ៦- លោក រឹម វីរៈ | ជំនួយការមេធាវី |

២- **ភាគីកម្មករនិយោជិត**

**ក/. សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ តាក ហ្វាត**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១២ ៩៨៨ ៦២៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី មាស វណ្ណី មន្ត្រី CCAWDU

២- លោក អែម សុភ័ក្ត្រា មន្ត្រី CCAWDU

៣- លោក មាស សម្ផស្ស ប្រធានសហជីព ស៊ីខៅឌូ នៃរោងចក្រ តាក ហ្វាត

៤- លោក លី វណ្ណារ៉ូ អនុប្រធានសហជីព

៥- លោក អ៊ុំ សុខសាន លេខាធិការសហជីព

៦- លោក សេង ណារិទ្ធិ ប្រតិភូបុគ្គលិក

៧- លោក ហាវ ម៉េងហ៊ា ប្រតិភូបុគ្គលិក

**ខ/. សហជីពកម្មករនិយោជិតនៃរោងចក្រ តាក ហ្វាត**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៧៧២ ៤៥៨ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី អ៊ុំ ផល្លា ប្រធានសហជីពកម្មករនិយោជិត

២- លោក ម៉ា សុភាព អនុប្រធានសហជីព

**គ/. សហជីពពន្លឺថ្មីនៃរោងចក្រ តាក ហ្វាត**

អាសយដ្ឋាន : ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៦ ៧៦៧ ០៧០ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក គីម ឌិច ប្រធានសហជីពពន្លឺថ្មី នៃរោងចក្រ តាកហ្វាត

២- លោក អ៊ុំ សារុំ ទីប្រឹក្សាសហជីព

**ឃ/. សហជីពអភិវឌ្ឍន៍កម្មករកាត់ដេរនៃរោងចក្រ តាក ហ្វាត**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៩២ ៦៦០ ៨៧០ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី រស់ កាន អនុប្រធានសហព័ន្ធ NIFTUC

២- លោក សុំ ស៊ីន ប្រធានសហជីពអភិវឌ្ឍន៍កម្មករកាត់ដេរ

៣- លោក សុង ស៊ីម អនុប្រធានសហជីព

៤- លោក នាក់ នួន                                    មន្ត្រីសហព័ន្ធ

**ង/. សហជីពឃុំវ៉ជនខ្មែរនៃរោងចក្រ តាក ហ្វាត**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៤៣៥ ៤៦៦                    លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **អវត្តមាន**

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

បច្ចុប្បន្ននេះ នៅទីតាំងក្រុមហ៊ុន តាក ហ្វាត មានបីអគារ (អគារ២, អគា៣ និងអគារ៥ជាន់) ហើយក្រុមហ៊ុនសំណូមពរឱ្យបងប្អូនកម្មករនិយោជិតទៅធ្វើការនៅអគារ៥ជាន់ (ប្តូរកម្មករនិយោជិតពីអគារ២ ទៅអគារ៥ជាន់) ដោយអនុវត្តតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ដោយហេតុថា ក្រុមហ៊ុនត្រូវធ្វើការជួសជុលអគារ២ ដែលមានសភាពចាស់ និងទ្រុឌទ្រោម ហើយការផ្លាស់ប្តូរកម្មករនិយោជិតទៅអគារ៥ជាន់ ក្រុមហ៊ុនសន្យាថា នឹងរក្សាអត្ថប្រយោជន៍គ្រប់ប្រភេទ ដែលកម្មករនិយោជិតធ្លាប់ទទួលកន្លងមកនៅដដែល ដូចជាអតីតភាពការងារ ។

បងប្អូនកម្មករនិយោជិតទាំងអស់មិនអាចគោរពតាមការចាត់តាំងផ្លាស់ប្តូរទីតាំងទៅធ្វើការនៅអគារ៥ជាន់បានឡើយ ដោយហេតុថា កម្មករកម្មការិនីបាត់បង់សេចក្តីទុកចិត្តលើក្រុមហ៊ុន ព្រោះកន្លងមកមានការផ្លាស់ប្តូរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយជាច្រើនដង ដែលមិនគោរពកិច្ចសន្យារបស់ខ្លួន (ក្រុមហ៊ុនបានប្រាប់កម្មករថា ប្តូរជាលើកចុងក្រោយ) ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទី២(ខ)(មាត្រា៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៣១ ក.ប/អក/វ.ក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩។

**សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ( វេលាម៉ោង ០៨:០០ នាទី ព្រឹក )

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទរបស់ក្រុមហ៊ុន តាក ហ្វាត ស្តីពីករណីសូមឱ្យកម្មករនិយោជិតទៅធ្វើការនៅអគារ៥ជាន់ ដោយគោរពតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងារជាបន្តបន្ទាប់ និងជាលើកចុងក្រោយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាលើចំណុចវិវាទចំនួន០១ចំណុចនេះទេ។ ចំណុចមិនសះជាចំនួន០១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទីព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់អាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសាកសួរព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជាចំនួន០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម :

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកក្រុមហ៊ុន ជូនលោកមេធាវី ហ៊ំ ភា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។

២- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន តាក ហ្វាត ជូនលោកស្រី ម៉ែន សុគ្គា និង លោក លីវ ម៉ាន់ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។

៣- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ជូនលោក ជាតិ ខេមរា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។

៤- កំណត់ហេតុរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ក្រុមអន្តរាគមន៍ដោះស្រាយកូដកម្ម-បាតុកម្ម នៅក្រុមហ៊ុន តាក ហ្វាត ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ។

៥- លិខិតរបស់នាយកក្រុមហ៊ុន តាក ហ្វាត គោរពជូន ឯកឧត្តមប្រធានគណៈកម្មាធិការដោះស្រាយកូដកម្ម បាតុកម្មតាមគ្រប់មុខសញ្ញា ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការស្នើសុំចុះត្រួតពិនិត្យការអនុវត្តនីកិច្ចព្រមព្រៀង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ របស់កម្មករ និងក្រុមហ៊ុន តាកហ្វាត ។

៦- សេចក្តីប្រកាសរបស់ក្រុមហ៊ុន តាក ហ្វាត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន តាក ហ្វាត ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន តាក ហ្វាត ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ។

៩- រូបថតចំនួន ១៤ សន្លឹក (បង្ហាញពីសភាពចាស់ទ្រុឌទ្រោមរបស់អគារទី២ និងទី៣) ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

**- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ តាក ហ្វាត**

១- សារណាការពារលើសំណុំរឿងលេខ ៨៩/០៩ នៃរោងចក្រ តាក ហ្វាត លេខ ០៧៧/០៩ ស.ប.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ។

២- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារលេខ ៨៣៨ កប/អក/វក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៩ ជំរាបមកលោកប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ តាក ហ្វាត ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី២ ។

៣- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ តាក ហ្វាត លេខ ៤៨២ សកបយ.អក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ ។

**- សហជីពកម្មករនិយោជិតនៃរោងចក្រ តាក ហ្វាត : គ្មាន**

**- សហជីពពន្លឺថ្មីនៃរោងចក្រ តាក ហ្វាត : គ្មាន**

**- សហជីពអភិវឌ្ឍន៍កម្មករកាត់ដេរនៃរោងចក្រ តាក ហ្វាត : គ្មាន**

**- សហជីពយុវជនខ្មែរនៃរោងចក្រ តាក ហ្វាត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុនតាក ហ្វាត លេខ ៥៣១ កប/អក/វ.ក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន តាក ហ្វាត ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។



ARBITRATION COUNCIL

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៣០ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៣១ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៈ**

- បច្ចុប្បន្ននេះ ក្រុមហ៊ុន តាក ហ្វាត មានចំនួលកម្មករនិយោជិតសរុបប្រមាណ ២.០១១នាក់។
- ក្នុងចំណោមសហជីពទាំង ៥ ដែលមកចូលរួមក្នុងសវនាការនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ មិនមានសហជីពណាមួយមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទៈ ភាគីក្រុមហ៊ុនសំណូមពរឱ្យកម្មករនិយោជិតទៅបំរើការងារនៅអគារ៥ជាន់ ដោយអនុវត្តតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩**

- បច្ចុប្បន្ន នៅក្នុងទីតាំងក្រុមហ៊ុន តាក ហ្វាត មាន០៣អគារ ដែលស្ថិតនៅជិត១គ្នា គឺអគារទី២ អគារទី៣ និងអគារទី៥ ហើយក្រុមហ៊ុនបានស្នើសុំឱ្យកម្មករនិយោជិតទៅធ្វើការនៅអគារទី៥ ដែលមានកំពស់ ៥ជាន់ ពីព្រោះអគារទី២ និងអគារទី៣នោះមានសភាពចាស់ទ្រុឌទ្រោម អាចមានគ្រោះថ្នាក់ដល់កម្មករនិយោជិតនៅថ្ងៃណាមួយ ដូច្នេះហើយទើបក្រុមហ៊ុនសម្រេចធ្វើការជួសជុលអគារចាស់ទាំង០២ នេះ។
- ភាគីនិយោជកបញ្ជាក់ថា នៅពេលភ្លៀងធ្លាក់ម្តងៗ ទឹកលិចតាមដំបូល ធ្វើឱ្យប្រឡាក់ផលិតផល ឬក្រណាត់ ដែលយកមកដេរ ហើយលូរដែលនៅខាងក្រោម ក៏ផុលទឹកចេញមកក្រៅ បណ្ដាលឱ្យរំខានដល់សម្ភាក់ផលិតកម្មរបស់ក្រុមហ៊ុន។ ម្យ៉ាងវិញទៀត ស្ថានភាពបែបនេះអាចបណ្ដាលឱ្យអ្នកទិញមិនបញ្ជាទិញផលិតផល ដោយសារកម្មករនិយោជិតបំរើការនៅកន្លែងមិនមានសុវត្ថិភាព និងមិនស្អាត។
- រូបថតបញ្ជាក់ពីសភាពចាស់ទ្រុឌទ្រោមរបស់អគារទី២ និងទី៣ ដែលតម្រូវឱ្យមានការកែលំអរឡើងវិញ។
- ភាគីក្រុមហ៊ុនបានបន្តទៀតថា ការផ្លាស់ប្តូរកម្មករនិយោជិតទៅធ្វើការនៅអគារ៥ជាន់ ដែលស្ថិតនៅប្រមាណ៥ ទៅ១០ម៉ែត្រពីអគារចាស់នេះ ក្រុមហ៊ុននឹងរក្សាអត្ថប្រយោជន៍គ្រប់ប្រភេទ ដែលកម្មករ

និយោជិតធ្លាប់ទទួលបានពីមុនមក ។

- យោងតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៥ រវាងភាគីនិយោជក និងសហជីពទាំង៥ខាងលើ ត្រង់ចំណុចទី១ ចែងថា "*ចំពោះប្រាក់រង្វាន់អតីតភាពការងារចំនួន៥ដុល្លារសម្រាប់ខែឧសភា ឆ្នាំ ២០០៥ ក្រុមហ៊ុននឹងបើកជូននៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ទន្ទឹមនឹងនេះ កម្មករនិយោជិតទាំងអស់ ស្ម័គ្រចិត្តទៅធ្វើការនៅអគារ៥ជាន់ ចាប់ពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៥នេះតទៅ និងបញ្ចប់ក្នុងខែ កក្កដា ឆ្នាំ២០០៥។ ការណ៍នេះ ក្រុមហ៊ុននឹងរៀបចំទៅតាមដំណាក់ៗរហូតទាល់តែអស់ពីអគារចាស់*" ។
- កិច្ចព្រមព្រៀង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៥ នេះ ត្រូវបានបញ្ជាក់ឡើងវិញ ដោយកិច្ចព្រមព្រៀង ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៥។
- តាមការបញ្ជាក់របស់ក្រុមហ៊ុន និងដោយមានការឯកភាពពីតំណាងកម្មករនិយោជិត គិតមកដល់ថ្ងៃ សវនាការនេះ ប្រាក់រង្វាន់អតីតភាពការងារចំនួន៥ដុល្លារអាមេរិកសម្រាប់ខែឧសភានោះ បានបើកជូន កម្មករនិយោជិតអស់ហើយ គឺបើកប្រាក់ឱ្យអស់នៅត្រឹមថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥។
- តាមការបញ្ជាក់របស់កម្មករនិយោជិត និងដោយមានការឯកភាពពីភាគីក្រុមហ៊ុនផងនោះ កម្មករទាំង អស់បានទៅធ្វើការនៅអគារ៥ជាន់អស់ហើយ រហូតមកដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥នេះ ពោលគឺ ពុំមានកម្មករនិយោជិតណាម្នាក់នៅធ្វើការនៅអគារចាស់ទៀតទេ សព្វថ្ងៃនេះ។
- ភាគីនិយោជកបានលើកឡើងថា កង្វល់ពិតប្រាកដរបស់ភាគីនិយោជកគឺថា ថ្វីបើកម្មករនិយោជិតទៅ បំរើការងារនៅអគារទី៥ក៏ពិតមែន ប៉ុន្តែកម្មករនិយោជិតមិនបានបំពេញការងារឱ្យអស់ពីកំលាំងកាយ ចិត្តនោះទេ គឺមកតែកាយ តែចិត្តនឹងអារម្មណ៍ធ្វើការមិនមាននៅក្នុងខ្លួន ហើយផលិតផលក៏មិនសម ល្មមនឹងអ្វីដែលកម្មករនិយោជិតគួរតែអាចធ្វើបាននោះដែរ។
- ភាគីកម្មករនិយោជិតបានជំទាស់នឹងការលើកឡើងនេះ ដោយហេតុថា ម៉ូតខោអាវថ្មី ដែលតម្រូវឱ្យ កម្មករនិយោជិតធ្វើនោះ គឺ ខុសពីម៉ូត ដែលកម្មករធ្វើកាលពីមុន ទាំងក្រណាត់ និងម៉ូត។ ដូចនេះ កម្មករនិយោជិតត្រូវចំណាយពេលមួយចំនួន ដើម្បីអាចធ្វើការងារឱ្យបានលឿន និង ម្យ៉ាងទៀត កម្មករ និយោជិតយល់ឃើញថា ភាគីនិយោជកមិនបានគោរពតាមការសន្យារបស់ខ្លួននោះទេ ដោយប្តូរពួក គាត់ពីកន្លែងមួយទៅកន្លែងមួយទៀត ទោះបីខ្លួនធ្លាប់បានសន្យាថា ជាការផ្លាស់ប្តូរចុងក្រោយក្តី។ កម្មករនិយោជិតបញ្ជាក់ថា ពួកគាត់បាត់បង់សេចក្តីទុកចិត្តលើភាគីនិយោជកហើយ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទ : ភាគីក្រុមហ៊ុនសំណូមពរឱ្យកម្មករនិយោជិតទៅបំរើការងារនៅអគារ៥ជាន់ ដោយអនុវត្តតាមកិច្ច ព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៥**

នៅក្នុងសំណុំរឿងនេះ ផ្អែកតាមអង្គហេតុ ភាគីនិយោជកទាមទារឱ្យកម្មករនិយោជិតទៅបំរើការងារនៅ

អគារ៥ជាន់ ភាគីកម្មករនិយោជិតបានសម្រេចចិត្តទៅបំរើការងារនៅអគារនោះអស់ចាប់តាំងពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩។ ប៉ុន្តែកម្មករនិយោជិតនៅមិនសប្បាយចិត្តទាក់ទងនឹងការផ្លាស់ប្តូរនេះទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការផ្លាស់ប្តូរអគារធ្វើការរបស់កម្មករនិយោជិតនេះធ្វើឡើងស្របច្បាប់ដែរ រឺទេ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផ្លាស់ប្តូរកម្មករនិយោជិតទៅបំរើការងារនៅអគារ៥ជាន់ នេះបានធ្វើឡើងដោយស្របច្បាប់ និងសមហេតុសមផល ដោយមូលហេតុដូចខាងក្រោម :

មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារចែងថា *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្ររោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក ។"*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គិកណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមហេតុសមផល។ (សូមមើលសេចក្តីបង្គាប់ *អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីក ស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងប្លាល កូមារ៉ា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣, លេខ ១០៦/០៧-អ៊ីម និង វ៉ើ ទី៣ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣, លេខ ៨៤/០៨-ទ្រីនុងប្លាល់ កូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១៤១/០៨-ប៊ួមថេម ហេតុផលនៃ សេចក្តីសម្រេចចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៧/០៣ និង ១៨/០៣ ហ្វូហ៊ីង ហ្គាមេន ថា *"ក្នុងការចាត់ចែង ការផ្លាស់ប្តូរការងាររបស់កម្មករនិយោជិតក្នុងក្រុមហ៊ុន ភាគីនិយោជកអាចធ្វើទៅបាន ដរាបណាមិនមានប៉ះពាល់ដល់ការកាត់បន្ថយប្រាក់ឈ្នួល ការផ្លាស់ប្តូរទីកន្លែងការងារទៅឆ្ងាយពីកន្លែងដើម ការផ្លាស់ប្តូរពេលវេលាធ្វើការពីវេនថ្ងៃទៅយប់ ឬពីយប់ទៅថ្ងៃ មិនប៉ះពាល់ដល់ជំនាញវិជ្ជាជីវៈសំខាន់ៗ ពុំនោះទេត្រូវបានចាត់ទុកថា ជាការបំពានលើកិច្ចសន្យាការងារ ដែលតំរូវឱ្យគោរពទៅតាមនីតិវិធីនៃការបញ្ចប់កិច្ចសន្យាការងារ ។..."*

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និងកម្មករនិយោជិតបានឯកភាពថា ការផ្លាស់ប្តូរអគារធ្វើការនេះមិនប៉ះពាល់ដល់ការកាត់បន្ថយប្រាក់ឈ្នួល ការផ្លាស់ប្តូរទីកន្លែងការងារទៅឆ្ងាយពីកន្លែងដើម ការផ្លាស់ប្តូរពេលវេលាធ្វើការពីវេនថ្ងៃទៅយប់ ឬពីយប់ទៅថ្ងៃ មិនប៉ះពាល់ដល់ជំនាញវិជ្ជាជីវៈនោះទេ។ ភាគីនិយោជកលើកឡើងថា មូលហេតុនៃការផ្លាស់ប្តូរនេះ ពីព្រោះអគារទី២ និងអគារទី៣នោះ មានសភាពចាស់ទ្រុឌទ្រោម អាចមានគ្រោះថ្នាក់ដល់កម្មករនិយោជិតនៅថ្ងៃណាមួយ ដូច្នេះហើយទើបក្រុមហ៊ុនសម្រេចធ្វើការជួសជុលអគារចាស់ទាំង០២នេះ ដោយផ្លាស់កម្មករនិយោជិតទាំងអស់ឱ្យទៅធ្វើការនៅអគារ៥ជាន់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួល

រូបផតបញ្ជាក់ពីសភាពចាស់ទ្រុឌទ្រោមរបស់អគារទី២ និងទី៣ ដែលតម្រូវឱ្យមានការកែលំអរឡើងវិញ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីនិយោជកមានសិទ្ធិស្របច្បាប់ និងមានហេតុផលសមស្រប ក្នុងការផ្លាស់ប្ដូរកម្មករនិយោជិតទៅបំរើការងារនៅអគារទី ៥ ។

ម្យ៉ាងវិញទៀត បើយោងតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ រវាងភាគីនិយោជក និងសហជីពទាំងប្រាំខាងលើ ត្រង់ចំណុចទី ១ ចែងថា *"ចំពោះប្រាក់រង្វាន់អតីតភាពការងារចំនួន៥ដុល្លារ សម្រាប់ខែឧសភា ឆ្នាំ២០០៩ ក្រុមហ៊ុននឹងបើកជូននៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ទន្ទឹមនឹងនេះ កម្មករនិយោជិតទាំងអស់ស្ម័គ្រចិត្តទៅធ្វើការនៅអគារ ៥ ជាន់ ចាប់ពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ នេះតទៅ និងបញ្ចប់ក្នុងខែកក្កដា ឆ្នាំ២០០៩។ ការណ៍នេះ ក្រុមហ៊ុននឹងរៀបចំទៅតាមដំណាក់ៗ រហូតទាល់តែអស់ពីអគារចាស់។"* តាមរយៈកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិតទាំងអស់ បានស្ម័គ្រចិត្តយល់ព្រមទៅបំរើការងារនៅអគារ៥ជាន់នោះហើយដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញទៀតថា ការដែលកម្មករនិយោជិតទាំងអស់បានទៅធ្វើការនៅអគារ៥ជាន់ និងភាគីនិយោជកបានបើកប្រាក់អតីតភាពការងារ៥ដុល្លារអាមេរិកឱ្យកម្មករនិយោជិតទាំងអស់រួចហើយ គឺ ភាគីទាំងពីរបានគោរពតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ត្រឹមត្រូវហើយ។

ប៉ុន្តែ ភាគីនិយោជកបានបញ្ជាក់ថា ទោះបីជាកម្មករនិយោជិតយល់ព្រមផ្លាស់ប្ដូរក៏ដោយ ប៉ុន្តែកម្មករនិយោជិតមិនបានខិតខំធ្វើការដូចមុនទេ ភាគីកម្មករនិយោជិតជំទាស់ ដោយលើកហេតុផលថា ការដែលបរិមាណផលិតផលមានការថយចុះ ដោយសារតែម៉ូតសំលៀកបំពាក់ថ្មី ដែលមិនអាចឱ្យកម្មករនិយោជិតធ្វើការបានលឿនដូចម៉ូតខោអាវមុនៗបាន។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការផ្លាស់ប្ដូរកន្លែងធ្វើការពីកន្លែងមួយទៅកន្លែងមួយទៀត អាចបណ្ដាលឱ្យមានផលលំបាកសម្រាប់ភាគីនិយោជក និងកម្មករនិយោជិត ដែលអាចនឹងជួបប្រទះនឹងបញ្ហាមួយចំនួនដែលកើតចេញពីការផ្លាស់ប្ដូរនេះ។ តែទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនមានតួនាទីដោះស្រាយបញ្ហា ដែលកើតឡើងបណ្ដាលមកពីការបាត់បង់នូវជំនឿទុកចិត្ត ជាជាងចេតនារបស់កម្មករនិយោជិតមិនព្រមខិតខំធ្វើការដោយខ្លួនឯងនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីនិយោជកមានជំរើសស្របច្បាប់ជាច្រើន ដែលនិយោជកអាចកសាងទំនុកចិត្តឡើងវិញ ដល់ភាគីកម្មករនិយោជិតរបស់ខ្លួន ដើម្បីឱ្យពួកគាត់ខិតខំបំរើការងារដូចជា ការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្ត ការផ្លាស់ប្ដូររបៀបគិតប្រាក់ឈ្នួល ការផ្ដល់អត្ថប្រយោជន៍ផ្សេងៗដល់កម្មករនិយោជិត ដែលខិតខំបំរើការងារជាដើម។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះមិនចេញសេចក្ដីបង្គាប់ទាក់ទងនឹងការបារម្ភរបស់ភាគីនិយោជក ដែលយល់ឃើញថា កម្មករនិយោជិតមិនមានអារម្មណ៍ខិតខំធ្វើការឱ្យអស់ពីចិត្តថ្លើមនោះទេ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើកទឹកចិត្តឱ្យភាគីនិយោជកដោះស្រាយវិវាទនេះ ដោយពិគ្រោះយោបល់ជាមួយតំណាងកម្មករនិយោជិត

ដើម្បីមានកិច្ចប្រមព្រៀងណាមួយអាចអនុវត្តបានប្រកបដោយប្រសិទ្ធិភាព។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើកទឹកចិត្តផងដែរ ឱ្យភាគីនិយោជកជ្រើសរើសវិធីសាស្ត្រពន្យល់ណែនាំ និងពិភាក្សាជាមួយតំណាងកម្មករនិយោជិតពីដំណើរការនៃការផ្លាស់ប្តូរទីតាំងធ្វើការ នៅពេលមានការផ្លាស់ប្តូរកើតឡើង ដើម្បីឱ្យមានការយោគយល់គ្នាទៅវិញទៅមក។

សរុបសេចក្តីមក ដោយសារការទាមទាររបស់ភាគីនិយោជកត្រូវបានកម្មករនិយោជិត ធ្វើតាមរួចរាល់ហើយ ពោលគឺកម្មករនិយោជិតទាំងអស់បានទៅធ្វើការនៅអគារ៩ជាន់ទាំងអស់គ្នាចាប់តាំងពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ៨៩/០៩-តាក ហ្វាត នេះ ដោយសារវិវាទទាក់ទងនឹងការប្តូរអគារធ្វើការរបស់កម្មករនិយោជិតត្រូវបានដោះស្រាយរួចរាល់ហើយ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បិទសំណុំរឿងលេខ ៨៩/០៩-តាក ហ្វាត។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កែវ ខាច**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឡុង ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **អាំង អេងថុង**

ហត្ថលេខា: ------------------------------